**ឯកសារស្រាវជ្រាវសង្ខេប**

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

# តួនាទីរបស់តុលាការយុត្តិធម៌អន្តរជាតិ

# ក្នុងការដោះស្រាយជម្លោះអន្តរជាតិ

ស្រាវជ្រាវដោយ៖ មូសារ អ៊ីស្សាម

ខែតុលា ឆ្នាំ២០១៥

**វិទ្យាស្ថានសភាកម្ពុជា**

## កំណត់សម្គាល់

វិទ្យាស្ថានសភាកម្ពុជា (វ.ស.ក) គឺជាស្ថាប័នឯករាជ្យមួយដែលផ្តល់ការគាំទ្រដល់សភាកម្ពុជា តាមរយៈការផ្តល់នូវឯកសារស្រាវជ្រាវទៅតាមសំណើរបស់សមាជិក-សមាជិកា និងគណៈកម្មការជំនាញរបស់រដ្ឋសភា-ព្រឹទ្ធសភា ដែលមានការវិភាគទៅលើបញ្ហាដែលកំពុងតែកើតមាននៅពេលបច្ចុប្បន្ន និងដែលអាចនឹងកើតឡើងនាពេលអនាគតលើប្រធានបទការរៀបចំច្បាប់ និងគោលនយោបាយសាធារណៈ។ ឯកសារទាំងនេះផ្តល់នូវព័ត៌មានផ្សេងៗដែលពាក់ព័ន្ធនឹងការងារសភា និងការងារមណ្ឌល ឬភូមិភាគរបស់សមាជិក-សមាជិការសភា ក៏ប៉ុន្តែ រាល់អត្ថន័យដែលមាននៅក្នុងឯកសារទាំងនេះមិនមែនតំណាង ឬឆ្លុះបញ្ចាំងអំពីទស្សនៈផ្ទាល់របស់វិទ្យាស្ថានសភាកម្ពុជា សភា ឬសមាជិក-សមាជិកាណាម្នាក់នោះឡើយ។

ខ្លឹមសារនៃឯកសារទាំងនេះមានកំណត់នូវកាលបរិច្ឆេទរៀបចំច្បាស់លាស់ និងអាចប្រើប្រាស់សម្រាប់តែជាឯកសារយោងប៉ុណ្ណោះ។ ឯកសារទាំងនេះមិនមានគោលបំណងផ្តល់ប្រឹក្សាផ្នែកច្បាប់ ឬទៅលើគោលនយោបាយណាមួយឡើយ ហើយក៏មិនបានធ្វើការសិក្សាអោយបានគ្រប់ប្រធានបទ ឬរាល់ខ្លឹមសារលម្អិតដែលពាក់ព័ន្ធនឹងបញ្ហាដែលបានលើកឡើងនោះដែរ។

ខ្លឹមសារនៃឯកសារស្រាវជ្រាវនេះស្ថិតក្រោមច្បាប់ជាធរមានរបស់កម្ពុជា និងកិច្ចព្រមព្រៀងអន្តរជាតិស្តីពីសិទ្ធិអ្នកនិពន្ធ។ រាល់ការរៀបចំឡើងវិញដោយដកស្រង់នូវផ្នែកណាមួយឬខ្លឹមសារទាំងស្រុងនៃឯកសារស្រាវជ្រាវនេះ ត្រូវមានការអនុញ្ញាតពីវិទ្យាស្ថាន។

រក្សាសិទ្ធិ ឆ្នាំ២០១៥ វិទ្យាស្ថានសភាកម្ពុជា (វ.ស.ក)។

# មាតិកា

សេចក្តីផ្តើម ........ 1
១-កាតព្វកិច្ចក្នុងការស្វែងរកដំណោះស្រាយដោយសន្តិវិធីចំពោះជម្លោះអន្តរជាតិ ........ 1
២-ដំណើរការអភិវឌ្ឍយុត្តាធិការអន្តរជាតិ ........ 2
៣-ប្រភេទនៃយុត្តាធិការអន្តរជាតិ ........ 2
៤-កង្វះការរួបរួមគ្នារវាងយុត្តាធិការអន្តរជាតិ( Lack of unity among international jurisdictions) ........ 5
៤.១ តុលាការស្វយ័ត ........ 6
៤.១.១ តុលាការអចិន្ត្រៃយ៍យុត្តិធម៌អន្តរជាតិ (PCIJ) ........ 6
៤.១.២ សាលាក្តីអន្តរជាតិសម្រាប់ច្បាប់សមុទ្រ (ITLOS) ........ 6
៤.១.៣ តុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) ........ 6
៤.២ តុលាការអមអង្គការអន្តរជាតិ ........ 7
៤.២.១ តុលាការយុត្តិធម៌អន្តរជាតិ ( ICJ ) ........ 7
៤.២.២ កិច្ចព្រមព្រៀងស្តីពីវិធាន និងនីតិវិធី ដែលគ្រប់គ្រងលើការដោះស្រាយវិវាទរបស់អង្គការពាណិជ្ជកម្មពិភពលោក ( WTO ) ( កិច្ចព្រមព្រៀងស្តីពីការដោះស្រាយវិវាទរបស់អង្គការពាណិជ្ជកម្មពិភពលោក - DSU ) ( WTO Understanding on Rules and Procedures Governing the Settlement of Disputes ) ........ 7
៤.២.៣ តុលាការយុត្តិធម៌អឺរ៉ុប(ECJ) ........ 8
៤.៣ យុត្តាធិការដែលមានលក្ខណៈចាប់បង្ខំ ........ 8
៤.៣.១ យុត្តាធិការដែលបានព្រមព្រៀង៖ ICJ ........ 9
៤.៣.២ យុត្តាធិការដែលមានលក្ខណៈចាប់បង្ខំ ........ 10
៤.៤ យុត្តាធិការដែលមានគូវិវាទតែមួយប្រភេទ និងយុត្តាធិការដែលមានគូវិវាទច្រើនប្រភេទ ........ 11
៤.៤.១ យុត្តាធិការដែលមានគូវិវាទតែមួយប្រភេទ ( ICJ, ICC ) ........ 11
៤.៤.២ យុត្តាធិការដែលមានគូវិវាទច្រើនប្រភេទ ........ 11
៥. មធ្យោបាយដើម្បីឈានទៅដល់ការដោះស្រាយវិវាទអន្តរជាតិដោយសន្តិវិធី ........ 11
៥.១ គោលការណ៍នៃជម្រើសដោយសេរី ........ 11
៥.២ វិធីដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ និងតាមប្រព័ន្ធតុលាការ ........ 12
៥.២.១ វិធីដោះស្រាយវិវាទតាមប្រព័ន្ធតុលាការ ........ 12
៥.២.២ វិធីដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ........ 12
សេចក្តីសន្និដ្ឋាន ........ 13

# សេចក្តីផ្តើម

ឯកសារសង្ខេបនេះបង្ហាញជូនពីវិធីសាស្ត្រនានានៃការដោះស្រាយជម្លោះអន្តរជាតិតាមកាតព្វកិច្ចខាងផ្លូវច្បាប់ ស្វែងរកដំណោះស្រាយដោយសន្តិវិធី។ ឯកសារនេះក៏បានធ្វើការគូសបញ្ជាក់ផងដែរ អំពីកង្វះខាតឯកភាពក្នុងចំណោមយុត្តាធិការអន្តរជាតិ ក៏ដូចជាមធ្យោបាយផ្សេងៗគ្នានៅក្នុងវិធីសាស្ត្រដោះស្រាយជម្លោះ។ ចុងក្រោយបំផុត ឯកសារសង្ខេបនេះមានគោលដៅផ្តល់ឲ្យមានការយល់ដឹងប្រសើរជាងមុនអំពីតួនាទី និងវិធានការរបស់តុលាការយុត្តិធម៌អន្តរជាតិ (International Court  of Justice: ICJ)។

## ១-កាតព្វកិច្ចក្នុងការស្វែងរកដំណោះស្រាយដោយសន្តិវិធីចំពោះជម្លោះអន្តរជាតិ

មាត្រា២.៤ នៃធម្មនុញ្ញអង្គការសហប្រជាជាតិចែងថា «សមាជិករបស់ អ.ស.ប ត្រូវជៀសវាងការគំរាមគំហែង ឬការប្រើប្រាស់កម្លាំងទ័ពទៅរំលោភនឹងបូរណភាពទឹកដី ឬឯករាជ្យខាងនយោបាយរបស់រដ្ឋជាសមាជិកដទៃទៀត ក្នុងទំនាក់ទំនងអន្តរជាតិ ឬក្នុងទិដ្ឋភាពដទៃទៀតណាមួយដែលមិនសមស្រប ជាមួយនឹងគោលដៅរបស់អង្គការសហប្រជាជាតិ»។ ក្នុងន័យនេះរាល់ការផ្លាស់ប្តូរនានា អាចសម្រេចទៅបាន ដោយសារតែកិច្ចព្រមព្រៀង រីឯជម្លោះទាំងឡាយត្រូវដោះស្រាយដោយសន្តិវិធី[1]។ កាតព្វកិច្ចនេះត្រូវបានបញ្ជាក់យ៉ាងច្បាស់ក្នុងមាត្រា២.៣ នៃធម្មនុញ្ញអង្គការសហប្រជាជាតិដែលចែងថា៖ «រដ្ឋជាសមាជិកទាំងឡាយ ត្រូវតែដោះស្រាយជម្លោះអន្តរជាតិរបស់ខ្លួន ដោយមធ្យោបាយសន្តិវិធីដែលធ្វើយ៉ាងណាមិនឲ្យប៉ះពាល់ដល់សន្តិភាព សន្តិសុខ និងយុត្តិធម៌អន្តរជាតិ»។ តុលាការយុត្តិធម៌អន្តរជាតិតែងតែនិយាយយោងទៅលើកាតព្វកិច្ចនេះជាច្រើនលើកច្រើនសា[2]។ ក៏ប៉ុន្តែគោលការណ៍ដោះស្រាយជម្លោះដោយសន្តិវិធីនេះអនុវត្តបានតែនៅពេលដែលការបន្តជម្លោះទាំងនោះ មិនប៉ះពាល់ដល់ការរក្សាសន្តិភាព និងសន្តិសុខអន្តរជាតិ។ ប្រសិនបើជម្លោះអន្តរជាតិនោះ មានការប៉ះពាល់ដល់ការរក្សាសន្តិភាព និងសន្តិសុខអន្តរជាតិ រដ្ឋជាសមាជិកអាចប្រើប្រាស់មធ្យោបាយអសន្តិវិធីទៅតាមធម្មនុញ្ញអង្គការសហប្រជាជាតិ។

---

[1] The Hague Convention of 18 October 1907 for the settlement of international disputes initiated this principle. This requirement has since been enhanced, and its formulation has been better structured, particularly in the United Nations Charter.

[2] The International Court of Justice reminds it in the beginning of each of the ten orders for provisional measures made in the Kosovo case (Orders of 2 June 1999, § 31-32). In addition, the United Nations General Assembly made two important statements with regard to the judicial settlement:

- The Declaration on Principles of International Law concerning Friendly Relations and Cooperation among States in accordance with the UN Charter (resolution 2625 (XXV) of 24 October 1970),
- The Manila Declaration on the Peaceful Settlement of Disputes (Resolution 37/10 of 15 November 1982).

## ២-ដំណើរការអភិវឌ្ឍយុត្តាធិការអន្តរជាតិ

នៅសតវត្សរ៍ទី២០ គំនិតស្តីពីយុត្តិធម៌អន្តរជាតិបានរីកចម្រើន ហើយត្រូវបានបង្ហាញឲ្យឃើញពីការកកើតឡើងនូវយុត្តាធិការ ដែលមានចំនួនច្រើនគួរសមនៅក្នុងកំឡុងពេលថ្មីៗកន្លងទៅ។ កាតព្វកិច្ចដើម្បីដោះស្រាយជម្លោះដោយសន្តិវិធីបានបង្ហាញថាបច្ចុប្បន្ននេះការស្វែងរកយុត្តិធម៌ជាឧបករណ៍ដើម្បីរក្សាសន្តិភាព។ ក៏ប៉ុន្តែចៅក្រមអន្តរជាតិពុំមានអំណាចដូចជាចៅក្រមនៅថ្នាក់ជាតិឡើយ ដោយហេតុថាចៅក្រមអន្តរជាតិគឺពឹងផ្អែកទៅលើការយល់ព្រមរបស់បណ្តារដ្ឋនានា។ គួរកត់សំគាល់ផងដែរថា ការអភិវឌ្ឍន៍ឲ្យមានយុត្តាធិការកាន់តែច្រើន អាចមានផលប៉ះពាល់អវិជ្ជមានពីព្រោះដំណើរការនេះអាចនឹងកាត់បន្ថយឱកាសនៃការចរចារ ដំណោះស្រាយបែបមិត្តភាព និងអាចធ្វើឲ្យកាន់តែយឺតយ៉ាវដល់ការដោះស្រាយជម្លោះ។ ទោះបីជាមានការកើនចំនួនតុលាការនានានៅក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះក៏ដោយ ក៏តុលាការទាំងនេះមិនបានត្រូវរៀបចំដើម្បីក្លាយជាប្រព័ន្ធតុលាការសកលលោកមួយ ដែលតុលាការអន្តរជាតិទាំងនោះរួបរួមគ្នានៅក្នុងប្រព័ន្ធតែមួយគត់។

## ៣-ប្រភេទនៃយុត្តាធិការអន្តរជាតិ

បន្ទាប់ពីតុលាការយុត្តិធម៌អន្តរជាតិ ICJ គឺមានតែតុលាការអន្តរជាតិផ្នែកជំនាញទេ ដែលមានចំនួនកើនឡើង ព្រមទាំងមានលក្ខណៈសកល។ តុលាការអន្តរជាតិសម្រាប់ច្បាប់សមុទ្រ (International Tribunal for the Law of the Sea: ITLOS) គឺជាឧទាហរណ៍មួយនៃតុលាការផ្នែកជំនាញនេះ[3] ។ ដូចគ្នានេះដែរ តុលាការរដ្ឋបាលអន្តរជាតិក៏មានចំនួនកើនឡើងនៅក្នុងបណ្តាអង្គការអន្តរជាតិ។ ក្នុងពេលថ្មីៗនេះ យុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ បានបោះជំហានជាបន្ថែមដោយក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិបានបង្កើតតុលាការចំពោះកិច្ច (ad hoc tribunals) ចំនួនពីរ[4]។ លើសពីនេះបណ្តារដ្ឋនានា (ជាង ១២០ រដ្ឋ) បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយនៅទីក្រុងរ៉ូម កាលពីថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ១៩៩៨ ដើម្បីបង្កើតឲ្យមានតុលាការព្រហ្មទណ្ឌអន្តរជាតិ (International Criminal Court: ICC) ជាយុត្តាធិការអចិន្ត្រៃយ៍។ ជាមួយគ្នានេះដែរ ក៏មាននូវតុលាការនានាថ្នាក់តំបន់ដែលភាគច្រើនគឺផ្នែកជំនាញទាក់ទងដល់សិទ្ធិមនុស្ស[5]។ ចុងក្រោយនេះ នៅមានតុលាការអន្តរជាតិបែប «កូនកាត់» ដូចជាតុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន ឬអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

ប្រភេទនៃជម្លោះដែលតុលាការអន្តរជាតិទាំងនេះដោះស្រាយអាចមានចំណាត់ការបែបខុសៗគ្នាយ៉ាងខ្លាំង[6]។

---

[3] Subsequent to the entry into force of the Montego Bay Convention of 10 December 1982.
[4] One for the former Yugoslavia (Resolution 827 of May 25, 1993), the other for Rwanda (Resolution 955 of November 8, 1994).
[5] European Court of Human Rights, Inter-American Court of Human Rights, African Court on Human Rights.
[6] There are, for example, distinction for competency between validity and responsibility, civil or criminal.

| តុលាការអន្តរជាតិ ដែលមានអំណាចទូលំទូលាយ និងមានដែនយុត្តាធិការទូទាំង សាកលលោក ឬក្នុងតំបន់ | តុលាការអន្តរជាតិដែលមានផ្នែកជំនាញ និងដែនយុត្តាធិការទូទាំងសាកលលោក | តុលាការអន្តរជាតិដែលមានផ្នែកជំនាញ និងដែនយុត្តាធិការមានកម្រិត | តុលាការដែលមានផ្នែកជំនាញក្នុងតំបន់ | មជ្ឈត្តកម្ម |
|---|---|---|---|---|
| តុលាការយុត្តិធម៌អន្តរ-ជាតិ (ICJ) (កន្លងមកមានឈ្មោះជាតុលាការអចិន្ត្រៃយ៍យុត្តិធម៌អន្តរ-ជាតិ : PCIJ), តុលាការយុត្តិធម៌អាមេរិកកណ្តាល (Central American Court of Justice), តុលាការយុត្តិធម៌អន្តរ-ទ្វីបអាមេរិក (Inter American Court of Justice), តុលាការយុត្តិធម៌អន្តរជាតិឥស្លាម (Islamic International Court of Justice) | តុលាការអន្តរជាតិស្តីពីច្បាប់សមុទ្រ (ITLOS), អង្គភាពដោះស្រាយវិវាទសម្រាប់ច្បាប់ពាណិជ្ជកម្មអន្តរជាតិ (Dispute Settlement Body : DSB), តុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) សម្រាប់ច្បាប់មនុស្សធម៌ (Humanitarian Law) | <u>ច្បាប់មនុស្សធម៌</u>៖ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី (International Criminal Tribunal for former Yugoslavia), តុលាការព្រហ្ម-ទណ្ឌអន្តរជាតិសម្រាប់រវ៉ាន់ដា (International Criminal Tribunal for Rwanda : ICTR), សាលាក្តីព្រហ្មទណ្ឌអន្តរជាតិផ្សេងទៀត (នៅកម្ពុជា, សៀរ៉ា-ឡេអូន, កូសូវ៉ូ, ទីម័រខាងកើត) <u>ច្បាប់រដ្ឋបាលអន្តរជាតិ</u>៖ តុលាការរដ្ឋបាលរបស់អង្គការសហប្រជាជាតិ (United Nation Administrative Tribunal: UNAT), តុលាការរដ្ឋបាលរបស់ | <u>សិទ្ធិមនុស្ស</u>៖ តុលាការសិទ្ធិមនុស្សរបស់អឺរ៉ុប(European Court of Human Rights: ECHR), គណៈកម្មការសិទ្ធិមនុស្សអន្តរទ្វីបអាមេរិក(Inter-American Commission of Human Rights : IACHR), តុលាការសិទ្ធិមនុស្ស និងប្រជាជនទ្វីបអាហ្វ្រិក <u>សេដ្ឋកិច្ច</u>៖ តុលាការយុត្តិធម៌អឺរ៉ុប (European Court of Justice: ECJ), តុលាការយុត្តិធម៌ និងមជ្ឈត្តកម្ម OHADA, តុលាការយុត្តិធម៌នៃ ទីផ្សាររួម សម្រាប់អាហ្វ្រិកខាងកើត និងអាហ្វ្រិកខាងត្បូង(Court of Justice of Common Market for Eastern | <u>មជ្ឈត្តកម្មអន្តរជាតិទូទៅ</u>៖ តុលាការអចិន្ត្រៃយ៍នៃមជ្ឈត្តកម្ម (Permanent Court of Arbitration : PCA) ឬមជ្ឈត្តកម្ម*ចំពោះកិច្ច(ad hoc Arbitration)* <u>មជ្ឈត្តកម្មអន្តរជាតិផ្នែកជំនាញ</u>៖ មជ្ឈមណ្ឌលអន្តរជាតិសម្រាប់ការដោះស្រាយជម្លោះវិនិយោគទុន (International Center for the Settlement of Investment Disputes : ICSID), សាលាក្តីមជ្ឈត្តកម្មអ៊ីរ៉ង់-សហរដ្ឋអាមេរិក <u>មជ្ឈត្តកម្មក្នុងតំបន់</u>៖ តុលាការផ្សះផ្សារ និងមជ្ឈត្តកម្មរបស់ OSCE, គណៈកម្មការសម្រុះសម្រួល ផ្សះផ្សារ និងមជ្ឈត្តកម្មនៃអង្គការសាមគ្គីភាពអាហ្វ្រិក, ប្រព័ន្ធមជ្ឈ- |

| | | | | |
|---|---|---|---|---|
| | | អង្គការពលកម្មអន្តរជាតិ (International Labor Organisation Administrative Tribunal: ILOAT), តុលាការរដ្ឋបាលរបស់ធនាគារពិភពលោក។ តុលាការរដ្ឋបាលទាំងអស់មានចំនួន២៣។ | and Southern Africa), តុលាការយុត្តិធម៌នៃសហគមន៍សេដ្ឋកិច្ចនៃរដ្ឋនៅអាហ្វ្រិកកណ្តាល(Court of Justice of Economic Community of States Central Africa), តុលាការយុត្តិធម៌នៃសហភាព Arab Maghreb, ការិយាល័យច្បាប់នៃ APEC (សហគមន៍អាស៊ីប៉ាស៊ីហ្វិកខាងកើត) | ត្តកម្មសម្រាប់ដោះស្រាយវិវាទរបស់ NAFTA និងតុលាការមជ្ឈត្តកម្មអាមេរិកកណ្តាល និងទីផ្សាររួម។ |

## ៤-កង្វះការរួបរួមគ្នារវាងយុត្តាធិការអន្តរជាតិ( Lack of unity among international jurisdictions)

ដូចបានរៀបរាប់ខាងលើ ប្រភេទតុលាការអន្តរជាតិមានជាច្រើនប្រភេទ ប៉ុន្តែតុលាការនោះ ពុំមានការរួបរួមគ្នាក្នុងប្រព័ន្ធតុលាការតែមួយ។ ហើយពុំមានគំរូប្រព័ន្ធយុត្តិធម៌អន្តរជាតិ "ណាមួយ" ទេ ។ តុលាការនីមួយៗ ត្រូវបានបង្កើតឡើងដោយមានស្វ័យភាពផ្ទាល់ខ្លួន និងមានភាពឯករាជ្យពីគ្នាក្នុងដែនយុត្តាធិការរបស់ខ្លួន។ អាចនិយាយបានថាតុលាការទាំងនោះមិនស្ថិតនៅក្រោមចំណុះតុលាការដទៃទៀតទេ ហើយតុលាការមួយមិនចាំបាច់អនុវត្តតាមយុទ្ធសាស្រ្តរបស់តុលាការមួយទៀតឡើយ[7]។

គួរកត់សម្គាល់ថា អាចមានការប្រកួតប្រជែងគ្នាក្នុងចំណោមតុលាការនានា ហើយក៏អាចមានការខ្វែងគំនិតគ្នារវាងយុត្តាធិការ ឬយុទ្ធសាស្រ្តផងដែរ។ ទោះបីជាយ៉ាងណា ការប្រឈមនៃការខ្វែងគំនិតគ្នាដោយផ្ទាល់រវាងយុត្តាធិការនានា មានកម្រិតទាប ពីព្រោះគូវិវាទភាគច្រើន ពុំបានជ្រើសរើសយកចៅក្រមអន្តរជាតិទេដើម្បីដោះស្រាយជម្លោះ។ ទោះជាយ៉ាងនេះក្តី ការប្រឈមនៃការខ្វែងគំនិតគ្នាដោយប្រយោល អាចកើតមានច្រើនជាង នៅពេលដែលចៅក្រមពីររូប ធ្វើការជំនុំជម្រះលើទិដ្ឋភាពផ្សេងគ្នាក្នុងរឿងក្តីតែមួយ ឬនៅពេលដែលចៅក្រមពីររូប ធ្វើការជំនុំជម្រះក្តីលើអង្គច្បាប់តែមួយ[8]។ ជាក់ស្តែង តុលាការមានការប្រុងប្រយ័ត្នក្នុងការទប់ស្កាត់មិនឲ្យមានការខ្វែងគំនិតគ្នា។ គួរបញ្ជាក់ផងដែរថា ជាធម្មតាតុលាការអន្តរជាតិនានា ប្រើប្រាស់នូវយុទ្ធសាស្រ្តរបស់គ្នាទៅវិញទៅមក ជាពិសេសតុលាការភាគច្រើនប្រើប្រាស់យុទ្ធសាស្រ្តរបស់តុលាការដទៃទៀតដែលមានកិត្យានុភាព ឬអតីតភាពច្រើនជាង។ ឧទាហរណ៍ ស្ថាប័នដោះស្រាយបណ្តឹងឧទ្ធរណ៍របស់អង្គការពាណិជ្ជកម្មពិភពលោក បានដកស្រង់យុទ្ធសាស្រ្តជាច្រើនពីតុលាការយុត្តិធម៌អន្តរជាតិ ICJ [9]។

---

[7] Moreover, there is between them no coordination mechanism, like reference to preliminary question (*question préjudicielle*). Such absence cannot be explained by the fact that they have clearly partitioned areas of intervention but by the lack of full consolidation of international law.

[8] The risks of disputes, at their core, concern substantive law. It was thus observed that the European courts, ECHR and ECJ had already developed diverging jurisprudence of general international law, for example on the rules of treaty interpretation which had led to what so-called "war of human rights."

[9] Vigilance therefore essentially takes the form of a reverence to the ICJ. For example, the precautionary principle as a general principle of law or customary rule when it was raised before the WTO Appellate Body (European Communities - Measures Concerning Meat and Meat Products (Hormones), WT / DS26 / AB / R, WT / DS48 / AB / R). There are demonstrations of this kind in the decisions of the International Tribunal for the Law of the Sea or in the reports of the WTO Appellate Body, or in the decisions of criminal courts. The references to the jurisprudence of the PCIJ and the ICJ are common and abundant. Another example when ITLOS was referred in its judgment of 1 July 1999 in the case of the Vessel Saiga (No. 2) to the judgment of the PCIJ in the case concerning *Certain German Interests in Polish Upper Silesia* and the one made by the same court in the case of the *Chorzow Factory*, as well as the judgment of the ICJ in the *Gabcikovo-Nagymaros*..

### ៤.១ តុលាការស្វយ័ត

តុលាការស្វយ័ត រួមមានតុលាការអចិន្ត្រៃយ៍យុត្តិធម៌អន្តរជាតិ, សាលាក្តីអន្តរជាតិសម្រាប់ច្បាប់សមុទ្រ និងតុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលត្រូវពិពណ៌នាដោយសង្ខេប ដូចតទៅ ៖

#### ៤.១.១ តុលាការអចិន្ត្រៃយ៍យុត្តិធម៌អន្តរជាតិ (PCIJ)

ទោះបីជាលក្ខន្តិកៈរបស់តុលាការអចិន្ត្រៃយ៍យុត្តិធម៌អន្តរជាតិ ត្រូវបានអនុម័តជាឯកច្ឆ័ន្ទដោយមហាសន្និបាតនៃសម្ព័ន្ធប្រជាជាតិ (League of Nations) ក៏ដោយ ក៏តុលាការនេះ មានភាពឯករាជ្យតាមផ្លូវច្បាប់ ហើយកតិកាសញ្ញានៃសម្ព័ន្ធប្រជាជាតិ ពុំមានចែងអំពីតុលាការនេះទេ[10]។

#### ៤.១.២ សាលាក្តីអន្តរជាតិសម្រាប់ច្បាប់សមុទ្រ (ITLOS)

មូលហេតុចម្បងនៃការបង្កើតនៃសាលាក្តីនេះ គឺដោយសាររដ្ឋភាគខាងត្បូង (ជាពិសេស រដ្ឋនៅក្នុងទ្វីបអាហ្វ្រិក និងរដ្ឋនៅក្នុងតំបន់អាស៊ីអាគ្នេយ៍) មិនទុកចិត្តចំពោះតុលាការយុត្តិធម៌អន្តរជាតិ (ICJ) ដែលនៅពេលនោះ ប្រទេសទាំងនោះមិនពេញចិត្តយ៉ាងខ្លាំងទៅលើសាលក្រមរបស់តុលាការយុត្តិធម៌អន្តរជាតិ នៅក្នុងរឿងក្តី*អាហ្វ្រិកខាងត្បូងភាគខាងលិច (1966 South West Africa Cases)* ក្នុងឆ្នាំ១៩៦៦ ដែលបង្ហាញយ៉ាងច្បាស់នូវនិន្នាការអភិរក្សរបស់តុលាការយុត្តិធម៌អន្តរជាតិ។ ដូច្នេះនៅក្នុងពេលនោះ រដ្ឋភាគខាងត្បូង ចង់ឲ្យមានការបង្កើតឡើងនូវតុលាការដាច់ដោយឡែកមួយដែលមានឯកទេសផ្នែកច្បាប់សមុទ្រ ដោយមិនពឹងផ្អែកតុលាការយុត្តិធម៌អន្តរជាតិបន្តទៅទៀត សម្រាប់ដោះស្រាយជម្លោះរវាងរដ្ឋនឹងរដ្ឋ។ ការបង្កើតតុលាការនេះ បណ្តាលឲ្យមានរចនាសម្ព័ន្ធដ៏ស្មុគស្មាញមួយ ដែលអនុញ្ញាតឲ្យរដ្ឋដែលមានវិវាទទាក់ទងនឹងច្បាប់សមុទ្រ ជ្រើសរើសយកតុលាការណាមួយ ក្នុងចំណោមតុលាការអន្តរជាតិមួយចំនួន ដូចជាសាលាក្តីអន្តរជាតិសម្រាប់ច្បាប់សមុទ្រ (ITLOS) តុលាការយុត្តិធម៌អន្តរជាតិ (ICJ) ឬតុលាការមជ្ឈត្តកម្មនានា។ តុលាការនេះ មានដំណើរការពីថ្ងៃទី១ ខែតុលា ឆ្នាំ១៩៩៦ និងបានបញ្ចប់រឿងក្តីដំបូងរបស់ខ្លួននៅចុងឆ្នាំ១៩៩៧។

#### ៤.១.៣ តុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC)

តុលាការព្រហ្មទណ្ឌអន្តរជាតិ(ICC) ត្រូវបានបង្កើតឡើងដោយលក្ខន្តិកៈទីក្រុងរ៉ូម និងបានចូលជាធរមាននៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០២។ ប្រទេសកម្ពុជា បានចុះហត្ថលេខាលើលក្ខន្តិកៈនេះ នៅថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០០ និងបានផ្តល់សច្ចាប័ន នៅថ្ងៃទី៧ ខែមករា ឆ្នាំ២០០២។ តុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) មានភាពឯករាជ្យដាច់ចេញពីអង្គការ

---

[10] This solution is better understood if it is connected to the fact that the United States had not ratified the Covenant. It was indeed the intention of leaving them the possibility to be still party to the Statute of the PCIJ. But United States did not choose to be part of it, and this possibility was finally used by Monaco and Liechtenstein.

អន្តរជាតិផ្សេងទៀត[11] ហើយលក្ខន្តិកៈក្រុងរ៉ូម បានបង្កើតឡើងជាអង្គការអន្តរជាតិមួយ ដែលមានមុខងារជាតុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលនោះគឺជាទិសដៅតែមួយគត់របស់អង្គការនេះ។

## ៤.២ តុលាការអមអង្គការអន្តរជាតិ

តុលាការទាំងនេះមានចំនួនច្រើន ធៀបទៅនឹងតុលាការដែលបានរៀបរាប់ខាងលើ។ សូមបង្ហាញជូននូវតុលាការមួយចំនួន ដូចខាងក្រោម៖

### ៤.២.១ តុលាការយុត្តិធម៌អន្តរជាតិ ( ICJ )

មាត្រា៧.១ នៃធម្មនុញ្ញអង្គការសហប្រជាជាតិ កត់សម្គាល់ថាតុលាការនេះជាស្ថាប័នមួយក្នុងចំណោមស្ថាប័នសំខាន់ៗ ចំនួន៦ របស់អង្គការសហប្រជាជាតិ។ តុលាការយុត្តិធម៌អន្តរជាតិ គឺជាស្ថាប័នអចិន្ត្រៃយ៍ដែលមានចែងនៅក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ។ លើសពីនេះ មាត្រា៧.១ នេះ និងមាត្រា៩២ នៃធម្មនុញ្ញ ចែងថា តុលាការយុត្តិធម៌អន្តរជាតិ (ICJ) «គឺជាស្ថាប័នតុលាការចម្បងរបស់អង្គការសហប្រជាជាតិ»។នេះជាមួយផ្នែកដ៏សំខាន់មួយនៃប្រព័ន្ធដោះស្រាយវិវាទដោយសន្តិវិធី ដែលមានចែងក្នុងធម្មនុញ្ញ។ លើសពីនេះ លក្ខន្តិកៈរបស់តុលាការយុត្តិធម៌អន្តរជាតិ (ICJ) ត្រូវបានដាក់ជាឧបសម្ព័ន្ធនៃធម្មនុញ្ញអង្គការសហប្រជាជាតិ។ អាស្រ័យហេតុនេះ រដ្ឋដែលជាសមាជិករបស់អង្គការសហប្រជា-ជាតិ *តាមគោលការណ៍ច្បាប់* ក្លាយជាភាគីនៃលក្ខន្តិកៈរបស់តុលាការយុត្តិធម៌អន្តរជាតិ (ICJ) ដោយស្វ័យប្រវត្តិ។

ទោះបីជាតុលាការនោះជាស្ថាប័នដ៏សំខាន់មួយយ៉ាងណាក៏ដោយ ក៏ពុំមានន័យថាគឺជាយុត្តាធិការដែលមានលក្ខណៈចាប់បង្ខំឡើយ។ យុត្តាធិការ គឺផ្អែកលើកិច្ចព្រមព្រៀង ឬសេចក្តីប្រកាស ដែលនឹងត្រូវពិពណ៌នាក្នុងផ្នែក៤.៣.១ ខាងក្រោម។

### ៤.២.២ កិច្ចព្រមព្រៀងស្តីពីវិធាន និងនីតិវិធី ដែលគ្រប់គ្រងលើការដោះស្រាយវិវាទរបស់អង្គការពាណិជ្ជកម្មពិភពលោក ( WTO ) ( កិច្ចព្រមព្រៀងស្តីពីការដោះស្រាយវិវាទរបស់អង្គការពាណិជ្ជកម្មពិភពលោក - DSU ) ( WTO Understanding on Rules and Procedures Governing the Settlement of Disputes )

កិច្ចព្រមព្រៀងដ៏សំខាន់មួយ ដែលសម្រេចបានក្នុងឆ្នាំ១៩៩៤ (គឺសេចក្តីប្រកាសទីក្រុង Marrakesh ថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៩៤) ហើយបានដាក់បញ្ចូលនៅក្នុងធម្មមនុញ្ញអង្គការពាណិជ្ជកម្មពិភពលោក គឺកិច្ចព្រមព្រៀងស្តីពីវិធាន និង

[11] Although it has an agreement with the UN, and largely depends on, especially through the role of the Security Council.

នីតិវិធី ដែលគ្រប់គ្រងលើការដោះស្រាយវិវាទ (WTO Understanding on Rules and Procedures Governing the Settlement of Disputes)។ កិច្ចព្រមព្រៀងនេះ ត្រូវបានអនុវត្តដោយមានការគាំទ្រពីស្ថាប័នពិសេសមួយរបស់អង្គការពាណិជ្ជកម្មពិភពលោក (WTO) ដែលមានឈ្មោះថាស្ថាប័នដោះស្រាយវិវាទ (Dispute Settlement Body: DSB) ដែលមានតំណាងមួយរូប មកពីរដ្ឋនីមួយៗដែលជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោក (WTO)។ ដូច្នេះ ស្ថាប័ននេះគឺជាស្ថាប័ននយោបាយការទូតមួយប្រភេទ (political-diplomatic)។ អនុស្សរណៈនៃការយោគយល់គ្នា ក៏បានបង្កើតនូវស្ថាប័នអចិន្ត្រៃយ៍សម្រាប់ដោះស្រាយបណ្តឹងឧទ្ធរណ៍មួយ (Standing Appellate Body) និងគណៈកម្មការចំពោះកិច្ចផ្សេងៗ (Ad hoc Panels)។ ជាក់ស្តែង ស្ថាប័ននោះ គឺជាផ្នែកដ៏សំខាន់របស់អង្គការពាណិជ្ជកម្មពិភពលោក (WTO)។

### ៤.២.៣ តុលាការយុត្តិធម៌អឺរ៉ុប (ECJ)

តុលាការយុត្តិធម៌អឺរ៉ុប(ECJ) គឺជាស្ថាប័នអឺរ៉ុបមួយ ដែលគ្រប់គ្រងដោយសន្ធិសញ្ញាអឺរ៉ុប។ ទំនាក់ទំនងរវាង តុលាការយុត្តិធម៌អឺរ៉ុប(ECJ) និងសហភាពអឺរ៉ុប ពុំទាន់មានភាពច្បាស់លាស់ទាំងស្រុងនៅឡើយទេ។ តុលាការនោះ មានសមត្ថកិច្ចក្នុងវិស័យនានាទាក់ទងនឹងការថែរក្សាស្ថាប័ននានារបស់អឺរ៉ុប និងត្រួតពិនិត្យមើលលើលំហូរដោយសេរីនៃទំនិញ ប្រជាជន និងដើមទុន។

## ៤.៣ យុត្តាធិការដែលមានលក្ខណៈចាប់បង្ខំ

បញ្ហាដែលលើកឡើងនៅទីនេះ គឺភាពខុសគ្នារវាងយុត្តាធិការដែលបានព្រមព្រៀង និងយុត្តាធិការដែលមានលក្ខណៈចាប់បង្ខំ។ ចំពោះមជ្ឈត្តកម្ម បញ្ហានៃយុត្តាធិការ គឺមានភាពខុសគ្នា ពីព្រោះតុលាការមជ្ឈត្តកម្ម អាចអនុវត្តការងារបានដោយផ្អែកលើការយល់ព្រមពីរដ្ឋនានាតែប៉ុណ្ណោះ។

យុត្តាធិការដែលមានលក្ខណៈចាប់បង្ខំ គឺជាយុត្តាធិការរបស់តុលាការណាមួយដែលត្រូវបានទទួលស្គាល់*ជាទូទៅ* និងជាអន្តរជាតិក្នុងការដោះស្រាយវិវាទដែលមានលក្ខណៈជាក់លាក់មួយចំនួន។ យុត្តាធិការ ដែលមានលក្ខណៈចាប់បង្ខំ គឺជាយុត្តាធិការ ដែលទទួលអំណាចដោះស្រាយជម្លោះតាមករណីនីមួយៗ (case by case basis) និងបន្ទាប់ពីវិវាទបានកើតឡើងតែប៉ុណ្ណោះ។ ដូច្នេះ យុត្តាធិការអាចទទួលអំណាចបានតាមវិធីជាច្រើន។

ដោយសារតែតុលាការត្រូវបានបង្កើតឡើងដោយសន្ធិសញ្ញា រដ្ឋនីមួយៗមានសិទ្ធិចូលរួម ឬមិនចូលរួម។ ទោះបីគេអាចយល់ថាតុលាការ មានលក្ខណៈចាប់បង្ខំចំពោះភាគីនៃសន្ធិសញ្ញាក៏ដោយ ប៉ុន្តែរដ្ឋនីមួយៗនៅតែអាចធ្វើការសម្រេចចិត្តទទួលយក ឬមិនទទួលយកយុត្តាធិការដែលមានលក្ខណៈចាប់បង្ខំនេះ (ឧទាហរណ៍ តុលាការយុត្តិធម៌អន្តរជាតិ) ឬអាចធ្វើការជ្រើសរើស រវាងតុលាការនានា (ឧទាហរណ៍ តុលាការអន្តរជាតិស្តីពីច្បាប់សមុទ្រ)។ ទោះជាយ៉ាងនេះក្តី នាពេលបច្ចុប្បន្ន ក្នុងប្រព័ន្ធច្បាប់អន្តរជាតិមានយុត្តាធិការជាច្រើនដែលមានលក្ខណៈចាប់បង្ខំ ហើយរដ្ឋជាសមាជិកនៃ

អង្គការមួយ ពុំមានជម្រើសក្រៅពីទទួលយកយុត្តាធិការនៃអង្គការនោះឡើយ (ឧទាហរណ៍ ស្ថាប័នដោះស្រាយវិវាទ (DSB) តុលាការយុត្តិធម៌អឺរ៉ុប(ECJ) និងតុលាការសិទ្ធិមនុស្សរបស់អឺរ៉ុប(ECHR) ចាប់តាំងពីអនុម័តនូវពិធីសារ ១១ នៃកតិកាសញ្ញាស្តីពីសិទ្ធមនុស្ស និងសិទ្ធិជាសារវ័ន្ត)។

## ៤.៣.១ យុត្តាធិការដែលបានព្រមព្រៀងៈ ICJ

ជាគោលការណ៍ យុត្តាធិការដែលបានព្រមព្រៀង គឺការព្រមទទួលយកយុត្តាធិការនោះ។ អាចនិយាយម៉្យាងទៀតថា រដ្ឋមួយ មិនអាចត្រូវគេប្ដឹងទៅកាន់តុលាការឡើយ ប្រសិនបើរដ្ឋនោះ មិនយល់ព្រមទទួលយកយុត្តាធិការនោះទេ។ បញ្ហានេះ ត្រូវបានតុលាការយុត្តិធម៌អន្តរជាតិ (ICJ) ធ្វើការបញ្ជាក់យ៉ាងច្បាស់ជាច្រើនលើកច្រើនសារមកហើយ[12]។ វិធីសាស្ត្រជាច្រើន ត្រូវបានអនុវត្តដើម្បីបង្កើតយុត្តាធិការដែលមានលក្ខណៈចាប់បង្ខំរបស់តុលាការ រួមមាន៖

### ៤.៣.១.១ តាមរយៈកិច្ចព្រមព្រៀងចំពោះកិច្ច( ad hoc) ដែលបានធ្វើឡើងដោយភាគី បន្ទាប់ពីវិវាទ បានកើតឡើង ដែលជាស្ថានភាពដែលមានលក្ខណៈងាយស្រួលបំផុតចំពោះតុលាការ[13]

មកដល់ពេលបច្ចុប្បន្ន មានរឿងក្ដីចំនួន១៥ នៅចំពោះមុខតុលាការ តាមរយៈការព្រមព្រៀងរួម ក្នុងនោះមានរឿងក្ដីសំខាន់ៗ ដូចជា រឿងក្ដី *ផ្ទៃដីក្រោមទឹកសមុទ្រខាងជើង (ឆ្នាំ១៩៦៩), ផ្ទៃដីក្រោមទឹក រវាងប្រទេសទុយនីស៊ី និងប្រទេសលីប៊ី (ឆ្នាំ១៩៨២), ជម្លោះដែនដី រវាងប្រទេសលីប៊ី និងប្រទេសឆាដ ឬគម្រោង រវាងប្រទេសហុងគ្រី និងប្រទេសស្លូវ៉ាគី (ឆ្នាំ១៩៩៧)*(1969 North Sea Continental Shelf, 1982 Continental Shelf Tunisia - Libya, 1997 Territorial Dispute Chad - Libya or Project Gabcikovo-Nagymaros Hungary - Slovakia)។

### ៤.៣.១.២ តាមរយៈការដាក់បញ្ចូលជំពូកស្ដីពីមជ្ឈត្តកម្មទៅក្នុងសន្ធិសញ្ញាណាមួយ (យោងតាមតុលាការយុត្តធម៌អន្តរជាតិ សន្ធិសញ្ញាទ្វេភាគី ឬពហុភាគីបែបនេះ មានចំនួនប្រហែល២៦០)[14]

អនុសញ្ញាដែលបានដាក់បញ្ចូលជំពូកស្ដីពីមជ្ឈត្តកម្មភាគច្រើន គឺជាកិច្ចព្រមព្រៀងធម្មតាស្តីពីពាណិជ្ជកម្មរវាងរដ្ឋនិងរដ្ឋ ប៉ុន្តែនាពេលថ្មីៗនេះ អនុសញ្ញាពហុភាគីនានា ដែលមានកម្មវត្ថុទូលំទូលាយកាន់តែច្រើនឡើងៗ បានផ្ដល់យុត្តាធិការឲ្យតុលាការយុត្តិធម៌អន្តរជាតិផងដែរ[15]។

---

[12] See, for example: PCIJ, *Chorzow Factory*, judgment of 13 September 1928: Series A, No. 17, p. 37.
[13] Compromise is provided for in Article 40 of the Statute.
[14] Some traps are for States, like the 1963 Protocol - now denounced by the United States – on the Convention on Consular Relations. These treaties are sometimes old treaties which established the jurisdiction of the PCIJ before the war and which have not been broken off since. Because of the succession from the PCIJ to the ICJ, these treaties are still valid. For example, France and Canada are still bound by a treaty of 12 May 1933 concerning the rights of national and issues of trade and navigation which includes an Article 20 providing for the jurisdiction of the PCIJ.

### ៤.៣.១.៣ តាមរយៈការចូលរួមក្នុងកិច្ចព្រមព្រៀងស្តីពីការដោះស្រាយវិវាទ

នេះពុំមែនជាជំពូកមួយស្តីពីមជ្ឈតកម្មឡើយ ដោយហេតុថាកម្មវត្ថុទាំងមូលនៃសន្ធិសញ្ញានេះគឺដោះស្រាយវិវាទ។ ទោះជាយ៉ាងណាក្តី យុត្តាធិការរបស់តុលាការយុត្តិធម៌អន្តរជាតិ មានអនុភាពដូចគ្នា។

### ៤.៣.១.៤ ឬតាមរយៈសេចក្តីប្រកាសជាជម្រើសនៃការទទួលយកយុត្តាធិការដែលមានលក្ខណៈចាប់បង្ខំ

នេះគឺវិធីដែលមានភាពងាយស្រួលជាងគេ។ សេចក្តីប្រកាសជាឯកតោភាគី (យោងតាមមាត្រា៣៦.៣) បញ្ជាក់អំពីប្រភេទនៃជម្លោះដែលត្រូវបញ្ជូនទៅតុលាការ សុពលភាព (ជាទូទៅ៥ ឬ១០ឆ្នាំ) និងរយៈពេលជូនដំណឹងដើម្បីឲ្យរដ្ឋបញ្ជាក់ជាមុនអំពីគម្រោងរបស់ខ្លួននៃការឈប់ទទួលស្គាល់យុត្តាធិការរបស់តុលាការ។

### ៤.៣.២ យុត្តាធិការដែលមានលក្ខណៈចាប់បង្ខំ

យុត្តាធិការដែលមានលក្ខណៈចាប់បង្ខំ គឺមានយន្តការងាយស្រួលបំផុត។ រដ្ឋដែលជាភាគីក្នុងកិច្ចព្រមព្រៀងបញ្ជាក់ពីប្រព័ន្ធដោះស្រាយជម្លោះមួយ ពុំមានជម្រើសឡើយ ហើយរឿងក្តី នឹងត្រូវបញ្ជូនជាស្វ័យប្រវត្តិទៅកាន់តុលាការដែលបានកំណត់ទុកជាមុននៅក្នុងកិច្ចព្រមព្រៀងនោះ។

### ៤.៣.២.១ កិច្ចព្រមព្រៀងស្តីពីវិធាន និងនីតិវិធី ដែលគ្រប់គ្រងលើការដោះស្រាយវិវាទរបស់អង្គការពាណិជ្ជកម្មពិភពលោក (WTO)(កិច្ចព្រមព្រៀងស្តីពីការដោះស្រាយវិវាទរបស់អង្គការពាណិជ្ជកម្មពិភពលោក - DSU)

យុត្តាធិការនៃស្ថាប័នដោះស្រាយវិវាទ (DSB) មានលក្ខណៈចាប់បង្ខំ និងពុំត្រូវការការយល់ព្រមបន្ថែមពីរដ្ឋដែលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក (WTO) ឡើយ។ ស្ថាប័នតុលាការនេះ(DSB) គឺជាផ្នែកមួយនៃ «កញ្ចប់» ដែលស្ថិតនៅក្រោមគោលការណ៍នៃការយល់ព្រមតែមួយ ដែលហាមឃាត់មិនឲ្យធ្វើការជ្រើសរើសស្ថាប័នតុលាការណាមួយក្នុងចំណោមស្ថាប័ននានារបស់អង្គការពាណិជ្ជកម្មពិភពលោក (WTO)។

---

[15] Thus, there are the jurisdiction of the Court for the 1980 Convention on the Conservation of Flora and Fauna of Antarctica; the 1988 Convention on the Fight against Illicit Traffic in Narcotic Drugs and Psychotropic Substances and the 1989 Convention against the recruitment and use of mercenaries. The most famous of these multilateral treaties providing for the jurisdiction of the Court is probably the Vienna Convention of 1969 on the Law of Treaties which indicates the possibility of seizing the Court in its Article 66 in case of dispute on *jus cogens* (with an alternative possibility for arbitration). This clause was even the condition of acceptance of the concept of *jus cogens* by the West.
The jurisdiction of the Court provided for in such treaties is not an academic question. Thus, Libya has relied on a clause in the Montreal Convention of 1971 on the Suppression of Unlawful Acts against the Safety of Civil Aviation, to refer to the Court in the dispute which opposed the US and in the UK in the so-called *Lockerbie* case.

## ៤.៤ យុត្តាធិការដែលមានគូវិវាទតែមួយប្រភេទ និងយុត្តាធិការដែលមានគូវិវាទច្រើនប្រភេទ

### ៤.៤.១ យុត្តាធិការដែលមានគូវិវាទតែមួយប្រភេទ ( ICJ, ICC )

មាត្រា៣៤ នៃលក្ខន្តិកៈរបស់តុលាការយុត្តិធម៌អន្តរជាតិ (ICJ) មានបញ្ជាក់យ៉ាងច្បាស់លើចំណុចនេះថា៖ មានតែរដ្ឋប៉ុណ្ណោះដែល«អាចជាភាគីនៅចំពោះមុខតុលាការ»។ យើងអាចនិយាយម៉្យាងទៀតថា បុគ្គលឯកជនឬអង្គការអន្តរជាតិមិនអាចជាភាគីនៃកិច្ចដំណើរការនីតិវិធីដោះស្រាយវិវាទនៅចំពោះមុខតុលាការយុត្តិធម៌អន្តរជាតិឡើយ។ ជាទូទៅ គេអាចពន្យល់បានថា មូលហេតុដែលបុគ្គលឯកជន ឬអង្គការអន្តរជាតិ មិនអាចជាភាគីនៅចំពោះមុខតុលាការនោះ គឺដោយសាររដ្ឋ មិនទុកចិត្តចំពោះអង្គការអន្តរជាតិនានា ជាពិសេស មានការបារម្ភថា ពួកគេអាចបង្កឲ្យមានវិវាទដែលរដ្ឋមិនចង់ឲ្យកើតមាន។ ក្រៅពីតុលាការយុត្តិធម៌អន្តរជាតិ (ICJ) តុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) ក៏ជាឧទាហរណ៍មួយទៀតនៃយុត្តាធិការដែលមានគូវិវាទតែមួយប្រភេទ (ភាគីគឺជាបុគ្គលពុំមែនជារដ្ឋឡើយ)។

### ៤.៤.២ យុត្តាធិការដែលមានគូវិវាទច្រើនប្រភេទ

យុត្តាធិការមួយចំនួនដូចជា DSU ឬ ITLOS អាចមានគូវិវាទច្រើនប្រភេទ (ជារដ្ឋ បុគ្គល ក្រុមហ៊ុនឯកជន)។

# ៥. មធ្យោបាយដើម្បីឈានទៅដល់ការដោះស្រាយវិវាទអន្តរជាតិដោយសន្តិវិធី

ទាក់ទងទៅនឹងការឈានទៅដល់ការដោះស្រាយវិវាទដោយសន្តិវិធី ភាគីដែលមានវិវាទ មានជម្រើសមួយចំនួន ដូចជាការសម្រេចចិត្តថាតើឲ្យភាគីទីបីចូលរួមដែរឬយ៉ាងណា ដំណោះស្រាយផ្អែកលើច្បាប់ ឬ ពុំផ្អែកលើច្បាប់ សេចក្ដីសម្រេចចិត្តដែលមានលក្ខណៈចាប់បង្ខំ ឬពុំមានលក្ខណៈចាប់បង្ខំ។ ជម្រើសទាំងនេះ ត្រូវបានពិភាក្សាខាងក្រោមនេះ៖

## ៥.១ គោលការណ៍នៃជម្រើសដោយសេរី

ក្រៅពីកិច្ចព្រមព្រៀងពិសេសដែលបានព្រមព្រៀងរវាងរដ្ឋដែលពាក់ព័ន្ធ មិនមានវិធីមួយណា ដែលត្រូវបានបង្កើតឡើងដើម្បីដោះស្រាយវិវាទផ្សេងៗឡើយ។ មាត្រា៣៣ នៃធម្មនុញ្ញអង្គការសហប្រជាជាតិ គិតគូរអំពីស្ថានភាពនេះ ដោយលើកឡើងនូវវិធីជាច្រើនដើម្បីដោះស្រាយវិវាទ[16] រួមមាន ការចរចារ ការសាកសួរព័ត៌មាន ការសម្រុះសម្រួល ការ

[16] The freedom of choice of means for settlement is provided explicitly in the Manila Declaration on the Peaceful Settlement of Disputes. Following its point I § 3, "international disputes shall be settled on the basis of sovereign equality of States and in accordance with the principle of free choice of means in accordance with obligations under the Charter of United Nations and with the principles of justice and international law ". In the same spirit as the Charter, the Declaration draws the attention of States "on the facilities offered by the International Court of Justice for the settlement of legal disputes" and provides with incentives for States to develop the jurisdiction of the Court (point II, § 5).

ផ្សះផ្សា មជ្ឈត្តកម្ម ការដោះស្រាយវិវាទតាមប្រព័ន្ធតុលាការ ឬវិធីដោះស្រាយវិវាទដោយសន្តិវិធីផ្សេងទៀត ដែលត្រូវបានជ្រើសរើសដោយភាគីដែលមានវិវាទ។

លើសពីនេះ រដ្ឋក៏អាចស្រុះស្រួលគ្នាតាមការព្រមព្រៀងពិសេស ដែលពួកគេនឹងប្រើប្រាស់ជាមធ្យោបាយជាក់លាក់មួយដើម្បីដោះស្រាយវិវាទ។

## ៥.២ វិធីដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ និងតាមប្រព័ន្ធតុលាការ

វិធីដោះស្រាយវិវាទដោយសន្តិវិធី ជាទូទៅត្រូវបានបែងចែកជាពីរប្រភេទ។ ទីមួយ គឺតាមរយៈនយោបាយ ឬការទូត ហើយមិនពាក់ព័ន្ធនឹងវិធានការតាមផ្លូវច្បាប់ឡើយ និងជាវិធីដែលឈានទៅរកដំណោះស្រាយ ដែលទាក់ទងនឹងនយោបាយ និងការទូត។ ការដោះស្រាយវិវាទតាមវិធីនេះ ជាទូទៅ ប្រើប្រាស់ការចរចារ ការសម្រុះសម្រួលដោយភាគីបី (good offices) ដែលមានឥទ្ធិពល ការសម្រុះសម្រួល ការស៊ើបអង្កេត និងការផ្សះផ្សារ។ វិធីទីពីរ គឺទាក់ទងនឹងវិធានការតាមផ្លូវច្បាប់។ នេះមានន័យថា ដំណោះស្រាយ គឺផ្អែកលើវិធានច្បាប់ ដូច្នេះវិធីនេះស្ថិតក្នុងគោលការណ៍ដោះស្រាយវិវាទតាមប្រព័ន្ធមជ្ឈត្តកម្ម ឬតាមប្រព័ន្ធតុលាការ។ ទាក់ទងនឹងចំណុចនេះ មាត្រា៣៨ នៃលក្ខន្តិកៈរបស់តុលាការយុត្តិធម៌អន្តរជាតិ ចែងថាតុលាការយុត្តធម៌អន្តរជាតិមានភារកិច្ច«ក្នុងការធ្វើសេចក្តីសម្រេច អនុលោមទៅតាមច្បាប់អន្តរជាតិ ដែលមានអានុភាពលើវិវាទទាំងនោះ»។

### ៥.២.១ វិធីដោះស្រាយវិវាទតាមប្រព័ន្ធតុលាការ

តាមវិធីនេះ ការដោះស្រាយវិវាទសំខាន់ៗមានពីរបែប គឺមជ្ឈត្តកម្ម និងការដោះស្រាយវិវាទតាមប្រព័ន្ធតុលាការ។ មជ្ឈត្តកម្ម ក៏ដូចជាការដោះស្រាយវិវាទតាមប្រព័ន្ធតុលាការជាទូទៅ អាចដោះស្រាយវិវាទបានយោងទៅលើច្បាប់អន្តរជាតិ និងមានលក្ខណៈចាប់បង្ខំចំពោះភាគី។ លក្ខណៈខុសគ្នានៃការដោះស្រាយវិវាទរវាងមជ្ឈត្តកម្ម និងការដោះស្រាយវិវាទតាមប្រព័ន្ធតុលាការ គឺថាតាមរយៈមជ្ឈត្តកម្ម សមាសភាពនៃស្ថាប័នមជ្ឈត្តកម្ម ត្រូវបានកំណត់ដោយភាគី ចំណែកឯតាមប្រព័ន្ធតុលាការមានការកំណត់ជាមុនរួចហើយនូវសមាសភាពនៃតុលាការ និងចៅក្រម (លើកលែងតែចៅក្រមចំពោះកិច្ច(ad hoc) នៅតុលាការយុត្តិធម៌អន្តរជាតិ)។

### ៥.២.២ វិធីដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

ប្រសិនបើមិនមានការហាមឃាត់តាមផ្លូវច្បាប់នោះទេ ជាធម្មតា វិធីផ្សេងៗ ត្រូវបានអនុវត្តដើម្បីដោះស្រាយវិវាទ។ នេះឆ្លុះបញ្ចាំងអំពីអាទិភាពទៅលើការអនុវត្តន៍ច្បាប់ជាក់ស្តែងច្រើនជាង ដែលគាំទ្រ ការដោះស្រាយវិវាទឲ្យមាន ប្រសិទ្ធភាព ដោយការអនុវត្តន៍ច្បាប់អន្តរជាតិនោះស្របទៅតាមដំណើរការនយោបាយ។ អាស្រ័យហេតុនេះ ជារឿយៗនៅ

ពេលដែលកំពុងធ្វើការដោះស្រាយតាមរយៈភាគីទីបី ឬ តាមផ្លូវតុលាការ ឬតាមវិធីណាមួយផ្សេងទៀត ភាគីនៅតែមានសិទ្ធិធ្វើការចរចារ ដើម្បីស្វែងរកកិច្ចព្រមព្រៀងប្រកបដោយការយោគយល់គ្នាមួយ។ ប្រសិនបើពួកគេទទួលជោគជ័យ ពួកគេនៅតែអាចបញ្ឈប់កិច្ចដំណើរការនីតិវិធីបាន។

ទីពីរ ពេលខ្លះ គេតម្រូវឲ្យប្រើប្រាស់វិធីសាស្រ្តផ្សេងៗដើម្បីដោះស្រាយវិវាទ។ ជារឿយៗ គេតម្រូវឲ្យខ្ទះខ្ទែងធ្វើការចរចារគ្នាតាមរយៈការសម្រុះសម្រួល ឬមជ្ឈត្តកម្ម មុនប្រើប្រាស់វិធីដោះស្រាយវិវាទតាមប្រព័ន្ធតុលាការ។ អាស្រ័យហេតុនេះ ជាការធម្មតា ដែលថាត្រូវខ្ទះខ្ទែងធ្វើការសម្រុះសម្រួល ផ្សះផ្សាគ្នា ឬដោះស្រាយតាមរយៈមជ្ឈត្តកម្មជាមុនសិន មុននឹងបញ្ជូនវិវាទទៅដោះស្រាយតាមប្រព័ន្ធតុលាការ[17]។

## សេចក្តីសន្និដ្ឋាន ជម្រើសគោលនយោបាយ

រដ្ឋជាសមាជិកអង្គការសហប្រជាជាតិ ត្រូវដោះស្រាយជម្លោះអន្តរជាតិរបស់ខ្លួនដោយសន្តិវិធី ដោយមិនបង្កឲ្យមានគ្រោះថ្នាក់ដល់សន្តិភាព សន្តិសុខ និងយុត្តិធម៌អន្តរជាតិ។ នេះគឺជាគោលបំណងរបស់តុលាការយុត្តិធម៌អន្តរជាតិ និងតុលាការអន្តរជាតិដទៃជាច្រើនទៀត។ ទោះបីជាយ៉ាងណាក៏ដោយ មានហេតុផលជាច្រើនកំពុងដាក់កម្រិតទៅលើតួនាទីរបស់តុលាការយុត្តិធម៌អន្តរជាតិ(ICJ) ដូចជា៖

- ចំនួនយុត្តាធិការអន្តរជាតិជាច្រើន
- គោលការណ៍នៃការជ្រើសរើសដោយសេរីរបស់រដ្ឋ និងអង្គការអន្តរជាតិ ក្នុងការប្តឹងទៅតុលាការនានា
- កង្វះការរួបរួមរវាងយុត្តាធិការអន្តរជាតិ និង
- គូវិវាទមានឱកាសជានិច្ចក្នុងការប្រើប្រាស់វិធីផ្សេងៗជាច្រើន ដើម្បីសម្រេចបាននូវដំណោះស្រាយវិវាទអន្តរជាតិដោយសន្តិវិធី ។

ទោះជាយ៉ាងនេះក្តី ជាទូទៅ តុលាការដទៃទៀតជាច្រើន និងតុលាការមជ្ឈត្តកម្មនានា ចាត់ទុកថាតុលាការយុត្តិធម៌អន្តរជាតិ (ICJ) គឺជាតុលាការគំរូមួយ ដោយសារកិត្យានុភាព ឬអតីតភាពរបស់តុលាការនេះដែលជះឥទ្ធិពល៕

ហេតុដូចនេះហើយ អ្វីដែលបានរៀបរាប់ខាងលើនេះ នាំឲ្យមានជម្រើសគោលនយោបាយមួយចំនួនដែលសមាជិកសភានៃរដ្ឋដែលជាសមាជិកអង្គការសហប្រជាជាតិ អាចយកទៅអនុម័តរួមមាន៖

- សមាជិកសភាជាតិអាចអនុម័តច្បាប់ និងបទប្បញ្ញត្តិស្តីពីការផ្តល់សច្ចាប័ន ដើម្បីផ្តល់ការយល់ព្រម និងបង្កើតយុត្តាធិការកំហិត ឬដាច់ខាតមួយនៃតុលាការយុត្តិធម៌អន្តរជាតិ ដើម្បីឲ្យរដ្ឋរបស់ពួកគាត់អនុវត្តការងារឲ្យកាន់តែប្រសើរក្នុងការស្វែងរកសន្តិភាព និងសន្តិសុខ

[17] See eg Article 26 of the Stockholm Convention of 15 December 1992 on Conciliation and Arbitration.

- ដោយសារ មានតែរដ្ឋជាសមាជិកប៉ុណ្ណោះ ដែលអាចជាភាគីនៅចំពោះមុខតុលាការយុត្តិធម៌អន្តរជាតិ ហេតុដូចនេះ ផលប្រយោជន៍របស់រដ្ឋត្រូវបានធានាការពារ និងមិនត្រូវបានដាក់ក្នុងភាពអាសន្ន ព្រោះថា អង្គការអន្តរជាតិទាំងឡាយអាចមានទំនាស់ផលប្រយោជន៍ (ឧទាហរណ៍៖ រវាង សហភាពអឺរ៉ុប និងរដ្ឋដែលជាសមាជិកនៃសហភាពអឺរ៉ុប គឺជាសេណារីយ៉ូដែលអាចកើតឡើងនៅចំពោះមុខតុលាការសិទ្ធិមនុស្សអឺរ៉ុប)។ ហេតុដូចនេះ សមាជិកសភាជាតិអាចផ្តល់ការគាំទ្រយុត្តាធិការរបស់តុលាការយុត្តិធម៌អន្តរជាតិ និង
- ដោយសារតែ តុលាការយុត្តិធម៌អន្តរជាតិ (ICJ) ព្រមទាំងយុត្តាធិការអន្តរជាតិផ្សេងទៀត មិនអាចដោះស្រាយជម្លោះអន្តរជាតិគ្រប់ករណី ហើយទាន់ពេលវេលា និងក្នុងរបៀបមួយដែលអាច សម្រេចបាននូវដំណោះស្រាយមួយប្រកបដោយការយោគយល់គ្នានោះ សមាជិកសភាជាតិ អាចផ្តល់ការគាំទ្រ គំនិតផ្តួចផ្តើមផ្សេងទៀត ដូចជា ការចរចារ សម្រុះសម្រួល សន្ធានកម្ម ឬ មជ្ឈត្តកម្មផងដែរ។

# ឯកសារយោង


- Berlia G., « La jurisprudence des tribunaux internationaux en ce qui concerne leur compétence », *RCADI*, 1955-II (88), La Haye.
- De Visscher Ch., *Problèmes d'interprétation judiciaire en droit international public*, Paris, 1963.
- Gowlland-Debbas V., « The Relationship between the ICJ and the Security Council in the Light of the Lockerbie Case ». *AJIL* 1994 (88).
- Jaenicke G., « International Public Order », *EPIL*, vol. 7 (1984).
- Plantey A., *La négociation internationale*, Principes et méthodes, Paris, 1980.
- Reuter P., « De l'obligation de négocier », *Mélanges G. Morelli*, Milan, 1975.
- Santulli C., Droit du contentieux international, *Montchrestien*, Paris, 2005.
- Soubeyrol J., « Forum prorogatum et CIJ : De la procédure contentieuse à la procédure consultative », *RGDIP* 1972 (76).
- Thirlway H., « The Law and Procedure of the International Court of Justice (1960-1989), Points of Substantive Law (Law of the Sea) », *BYIL* 1993 (64), cité : The Law (1993).